លេខ ១៦២ ថ្ងៃសុក្រ ទី០២ ខែកញ្ញា ឆ្នាំ២០០៥

ពត៌មានក្នុងប្រទេស

# សួនបណ្តុះកូនឈើ សម្តេច ហ៊ុន សែន ស្វាយរៀង ត្រូវបានសម្ពោធ

*លោក ជ័យ ភូមិពល AKP ភ្នំពេញ*

សួនបណ្តុះកូនឈើ សម្តេច ហ៊ុន សែន ស្វាយរៀង ដែលមានតម្លៃ ៧ម៉ឺនដុល្លារ ត្រូវបានសម្ពោធជាផ្លូវការកាលពីថ្ងៃទី ១ កញ្ញា ដោយសម្តេច ហ៊ុន សែន ដែលចាត់ទុកសមិទ្ធិផលនៃទីនោះថាជាការជ្រើសរើសទីតាំងដ៏ត្រឹមត្រូវ ។

សម្តេចនាយករដ្ឋមន្ត្រី មានប្រសាសន៍ថា សួនបណ្តុះកូនឈើនៅទីនេះ ជាការត្រឹមត្រូវ ព្រោះស្វាយរៀងជាខេត្តដែលខ្សត់ខ្សោយព្រៃឈើខ្លាំងជាងគេ ។

សួនបណ្តុះកូនឈើ សម្តេច ហ៊ុន សែន គឺជាសួនទី៤ ដែលសួនទី១នៅភ្នំប្រុស សួនទី២នៅជប់ក្នុងខេត្តកំពង់ចាម និងសួនទី៣នៅខេត្តពោធិសាត់ ដែលមានសមត្ថភាពផលិតកូនឈើសរុបប្រមាណ១,៨លានដើមក្នុងមួយឆ្នាំ២ ។ សួនទាំងនោះឧបត្ថម្ភដោយក្រុមហ៊ុនថ្នាំជក់អង់គ្លេសអាមេរិកកាំងកម្ពុជា ហើយត្រូវបានសរសើរដោយសម្តេច ហ៊ុន សែន ចំពោះការចូលរួមផ្តួចផ្តើមកម្មវិធីដាំដើមឈើក្រោមកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលព្រៃឈើ និងអាជ្ញាធរខេត្តមួយចំនួន ចាប់តាំងពីឆ្នាំ១៩៩៨មក ដែលរហូតមកដល់ឆ្នាំ២០០៤ រាប់ទាំងការដាំ និងការចែកចាយកូនឈើរបស់សួននៅខេត្តកំពង់ចាម និងខេត្តពោធិសាត់នោះ បានចំនួន ៥,៨លានដើមនៅទូទាំងប្រទេស ។

សម្តេចនាយករដ្ឋមន្ត្រីថ្លែងថា ក្រុមហ៊ុនថ្នាំជក់អង់គ្លេស បារាំង អាមេរិកកាំង ដែលមានភាពជាដៃគូជាមួយរាជរដ្ឋាភិបាលបានដើរចំទិសដៅ ។ សម្តេចមានប្រសាសន៍ថា គឺជាការអរគុណណាស់បើសិនជាដៃគូទាំងអស់ ទាំងផ្នែកឯកជន និងមិត្តភក្តិបរទេសមិនមកមើលម៉ោងយើង ហើយប្រាប់យើងថា ម៉ោងប៉ុន្មាននោះ ។

លោក អារិន អ៊ឹង អគ្គនាយកក្រុមហ៊ុនថ្នាំជក់អង់គ្លេស បារាំង អាមេរិកកាំង ថ្លែងថា សួនបណ្តុះកូនឈើ សម្តេច ហ៊ុន សែន ស្វាយរៀង គឺជាសួនដែលធំជាងគេបង្អស់ ដែលមានសមត្ថភាពផលិតកូនឈើបាន ១លានដើមក្នុងមួយឆ្នាំ២ ប៉ុន្តែនៅឆ្នាំដំបូងនេះ យើងបណ្តុះកូនឈើ៦០ម៉ឺនដើម ដែលរួមមានដើមអាកាស្យា ប្រេងខ្យល់ ស្តៅ ខ្នុរ ទៀបបារាំង ស្វាយ បេង អង្កាញ់ និង គរគី ជាដើម ។

លោក អារិន អ៊ឹង ថ្លែងថា យើងនឹងខិតខំប្រឹងប្រែងសហការផលិតកូនឈើសំរាប់ការដាំ និងចែកចាយនៅទូទាំងប្រទេសឱ្យបានប្រមាណ ២,៤លានដើមក្នុងមួយឆ្នាំៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ។

សម្តេចនាយករដ្ឋមន្ត្រីថ្លែងថា ថ្ងៃនេះ ខ្ញុំអរគុណចំពោះក្រុមហ៊ុនដែលបានដើរតួភាពជាដៃគូ ប៉ុន្តែភាពជាដៃគូមិនបានមកមើលម៉ោងខ្ញុំ ហើយប្រាប់ខ្ញុំថា ម៉ោងប៉ុន្មានទេ គឺបានសេចក្តីថា អស់លោកបានមកសិក្សាខ្លួនឯង ដាក់ទុនខ្លួនឯង ហើយចែកចាយជូនប្រជាជន ដូច្នេះអស់លោកមិនបាននាំយកជំនួនដែលបានជួយត្រឡប់ទៅប្រទេសអស់លោកវិញទេ ។ សម្តេចថ្លែងថា បើសិនជាផ្នែកឯកជន ក៏ដូចជាដៃគូអន្តរជាតិទាំងឡាយដែលចង់ផ្តល់ជំនួយ គឺផ្តល់បែបនេះ គឺជាការល្អណាស់ ។

សម្តេច ហ៊ុន សែន ថ្លែងថា ការបណ្តុះកូនឈើ ការដាំកូនឈើ ពុំមែនជារឿងថ្មីនោះទេ គឺយើងបានអនុវត្តជាច្រើនឆ្នាំមកហើយ ប៉ុន្តែជោគជ័យនៃការដាំដើមឈើឡើងវិញ គឺចាំបាច់ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ ។ សម្តេចបានបណ្តុះកូនឈើហើយផ្តល់ជូនប្រជាពលរដ្ឋដាំដោយមិនគិតថ្លៃ គឺជាជំហានទី១ ប៉ុន្តែជោគជ័យសំខាន់នោះ គឺត្រូវតែមានប្រជាពលរដ្ឋទទួលយកទៅដាំ បើមិនដូច្នេះទេ គឺមិនទទួលជោគជ័យឡើយ ។

សម្តេច ហ៊ុន សែន ថ្លែងថា អំពីការព្រួយបារម្ភនៃការកាប់ឈើធ្វើអូសដ៏ច្រើនសន្ធឹកសន្ធាប់ដោយសិប្បកម្មឡឥដ្ឋ ក្បឿង ឡធ្យូង ឡចំហុយថ្នាំជក់ ដែលជាការបំផ្លាញព្រៃឈើនោះ ។ សម្តេចបានផ្តល់អនុសាសន៍ឱ្យប្រើក្បឿង ឬឥដ្ឋផលិតនៅប្រទេសវៀតណាមវិញ ព្រោះគេផលិតបានថោកជាង ដោយគេប្រើថាមពលធ្យូងថ្មសំរាប់ការផលិត ។ បញ្ហានេះបើយើងមិនស៊ីជំរៅទេ គេអាចចោទប្រកាន់រដ្ឋាភិបាលថា គ្រាន់តែឥដ្ឋ ក្បឿង ក៏បណ្តោយឱ្យនាំចូលពីវៀតណាមដែរ ។ ប៉ុន្តែបញ្ហាសំខាន់ គឺយើងចង់ថែរក្សាព្រៃឈើដែលគេកាប់ធ្វើអូសនោះ សុទ្ធតែប្រភេទឈើតូចៗ ដែលធ្វើឱ្យឈើដុះលូតលាស់មិនទាន់ ។/

---

## រាជរដ្ឋាភិបាលមានវិធានការឧបត្ថម្ភធនដោយស្វាគត់ស្មៀម
## សំរាប់បញ្ហាប្រេងឡើងថ្លៃ

*លោក ជឹម ណារី AKP ភ្នំពេញ*

ឯកឧត្តម ទេសរដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ បានមានប្រសាសន៍ថា តំលៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិនឹងឡើងថ្លៃបន្តទៀត ហើយវិធានការរបស់រាជរដ្ឋាភិបាល គឺការឧបត្ថម្ភធនដោយស្វាត់ស្មៀមសំរាប់បញ្ហាប្រេងឡើងថ្លៃនេះ ។

ឯកឧត្តម គាត ឈន់ បានថ្លែងដូច្នេះ ដើម្បីបំភ្លឺទៅនឹងសំនួររបស់អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ក្នុងសម័យប្រជុំរដ្ឋសភា នាព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៥ នៅសាលប្រជុំរដ្ឋសភា ។

ឯកឧត្តម បានថ្លែងថា : ចំពោះមតិរបស់មជ្ឈដ្ឋានមួយចំនួនដែលលើកឡើងថា ការឡើងថ្លៃប្រេងឥន្ធនៈ គឺបណ្តាលមកពីការមិនអើពើរបស់ស្ថាប័នទទួលខុសត្រូវ មានការកំរិតពន្ធអាករខ្ពស់ពេក ហើយទស្សនៈដែលយល់ឃើញបែបនេះមិនមែនជាការត្រឹមត្រូវទេ ពីព្រោះថា រាជរដ្ឋាភិបាលពុំបានតំឡើងកាតព្វកិច្ចពន្ធ និងអាករឡើយ ផ្ទុយទៅវិញរក្សាមូលដ្ឋាននៃការយកពន្ធឱ្យនៅកំរិតថេរ ទោះបីតំលៃផលិតផលតេលសិលា (ប្រេង) ទាំងនោះឡើងថ្លៃជាបន្តបន្ទាប់ក៏ដោយ ។ ជាក់ស្តែងបច្ចុប្បន្ននេះ តំលៃគិតពន្ធគយនាំចូលលើប្រេងសាំងនៅទាបជាងតំលៃដើមលើទីផ្សារអន្តរជាតិដល់ទៅ ៣៣០ដុល្លារអាមេរិកក្នុងមួយតោន រីឯតំលៃគិតពន្ធនាំចូលលើប្រេងម៉ាហ្សូតនៅទាបជាងតំលៃទីផ្សារអន្តរជាតិដល់ទៅ ២៦៣ដុល្លារអាមេរិកក្នុងមួយតោន ។ ដូច្នេះផ្អែកតាមតួលេខប្រាក់ពន្ធ និងអាករក្នុងខែសីហា ឆ្នាំ២០០៥នេះ ឃើញថារាជរដ្ឋាភិបាលបានឧបត្ថម្ភធនតាមរយៈការធ្វើសម្បទានប្រាក់ពន្ធ និងអាករលើការនាំចូលប្រេងដោយបំពេញខាតជូនប្រជាពលរដ្ឋដោយស្ងប់ស្ងៀមប្រមាណ ២៦ពាន់លានរៀល ឬប្រមាណ ៦លាន ៣សែនដុល្លារអាមេរិកក្នុងខណៈពេលដែលតំលៃប្រេងលើផ្សារអន្តរជាតិចេះតែឡើងថ្លៃជាបន្តបន្ទាប់ ។

ឯកឧត្តម គាត ឈន់ បានលើកឡើងឱ្យដឹងថា : នៅក្នុងខែមករា ឆ្នាំ២០០៥ ប្រេងឆៅមានតំលៃ ៤៥ដុល្លារ ក្នុងមួយធុង ហើយរហូតមកដល់បច្ចុប្បន្ន ប្រេងបានឡើងរហូតដល់ប្រមាណ ៧០ដុល្លារអាមេរិក ក្នុងមួយធុង ពោលគឺបានឡើងថ្លៃចំនួន ៥០ភាគរយ ប៉ុន្តែប្រេងឆៅតាមស្ថានីយ៍ក្នុងប្រទេសរបស់យើង គឺកើនឡើង១៨% តែប៉ុណ្ណោះ ជាការឧបត្ថម្ភធនដ៏ស្ងាត់ស្ងៀមរបស់រាជរដ្ឋាភិបាល ។ ហើយក្នុងឆ្នាំ២០០៥នេះ កម្ពុជាមានការនាំចូលប្រេងគ្រប់ប្រភេទចំនួន ៦៣២ពាន់តោន ។ ចំពោះវិធានការមួយទៀតដែលរាជរដ្ឋាភិបាលប្រកាន់យកទៀតនោះ គឺការប្រើប្រាស់ធនធានរបស់រដ្ឋដោយកំរនោះឯង គឺការកាត់បន្ថយការប្រើប្រាស់នៅគ្រប់ក្រសួង ស្ថាប័ន ចំនួន ១០ភាគរយ ដោយការកាត់នេះ ដើម្បីទុកបំរុងសំរាប់បំរើឱ្យពេលមានគ្រោះធម្មជាតិ ជៀសវាងការប្រើប្រាស់ថវិការដ្ឋថ្មី ដោយសារមានគ្រោះធម្មជាតិពិសេសគ្រោះរាំងស្ងួត ហើយសូមអំពាវនាវឱ្យគ្រប់មជ្ឈដ្ឋានមានការសន្សំសំចៃសំរាប់ការប្រើប្រាស់ប្រេង ។ ឯកឧត្តម គាត ឈន់ ក៏បានបញ្ជាក់អំពីការបង្ក្រាបអំពើរត់ពន្ធប្រេងដែលក្នុងឆ្នាំ ២០០៤ កន្លងមក ចាប់បានចំនួន ១លាន ៥សែនលីត្រ និងដើមឆ្នាំ២០០៥នេះ បានចំនួនជាង ១លានលីត្រ ផងដែរ ។ម្យ៉ាងទៀត ឯកឧត្តម ក៏បានបញ្ជាក់ថា ប្រសិនបើយើងមិនយកពន្ធលើប្រេងឥន្ធនៈ សំដៅធ្វើឱ្យប្រេងចុះថ្លៃនោះគឺយើងនឹងបាត់ចំណូលពន្ធគយចំនួន ៣០% បានសេចក្តីថា ២% នៃ GDP ត្រូវបាត់ ហើយយើងខ្ញុំត្រូវរ៉ាប់រងប្រាក់ខែ ៤% នៃ GDP បាត់ប្រាក់ខែ ២% នៃផលិតផលសរុបក្នុងស្រុក តើទាជាចលាចលយ៉ាង

ម៉េចទៅ ! ក្នុងបរិការមួយដែលយើងខិតខំរក្សាស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ព្រមទាំងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីភាពបរិស្ថានរួមសំរាប់កំណែទំរង់ដើម្បីកសាងប្រទេសជាតិ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា : រដ្ឋាភិបាលបានដឹងច្បាស់ថា បើតំលៃប្រេងឥន្ធនៈឡើងពី ១៥ ទៅ ២០ភាគរយ វានឹងកាត់បន្ថយកំណើនសេដ្ឋកិច្ច ផ.ស.ស នោះ ចំនួន១ភាគរយ ក្នុងមួយឆ្នាំ ។ នៅឆ្នាំ២០០៤កន្លងមក ប្រទេសកម្ពុជាសំរេចបានកំណើនសេដ្ឋកិច្ច ១៣% តាមតំលៃចរន្ត ឬ ១២,៧៥% តាមតំលៃថេរ ។ ក្នុងបរិការដែលសន្ទុះគំហុកនៃការឡើងថ្លៃប្រេងឆៅលើឆាកអន្តរជាតិដោយមានកត្តាផ្សេងទៀតថែមទៀតផងនោះ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០០៥ យើងខ្ញុំគណនាថា នឹងសំរេចបានត្រឹមតែ ៦,៣% តាមតំលៃថេរតែប៉ុណ្ណោះ ។ គោលដៅរបស់រដ្ឋាភិបាល គឺកសាងសេដ្ឋកិច្ចមួយដែលមានកំណើនប្រកបដោយចិរភាព ពី ៦ ទៅ ៧% ក្នុងមួយឆ្នាំ ។ ប៉ុន្តែប្រសិនបើប្រេងឆៅឡើងហួស ៧០ដុល្លារអាមេរិក ក្នុងមួយធុង នៅក្នុងត្រីមាសទី៣នេះ តើអាចមានកំណើន ៦,៣% បាន ឬទេ ចំលើយជាវិជ្ជមានមិនស្ថិតតែលើកត្តាអត្តនោម័ត ឬផ្ទៃក្នុងរបស់យើងទេ គឺថាទោះបីរាជរដ្ឋាភិបាលប្រកាសអភិក្រមសកម្មគ្រប់គ្រងយ៉ាងណាក៏ដោយ ក៏កង្វល់អំពីការធានាកំណើននេះនៅតែមាន ។ ចំពោះអតិផរណាវិញ ប្តូរផ្តាច់របស់រាជរដ្ឋាភិបាល គឺខិតខំធ្វើឱ្យអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតនៅក្នុងកំរិត ៣ ទៅ ៤% ។ ដោយកត្តាតំលៃប្រេង និងកត្តារដូវកាល អាត្រាអតិផរណាប្រចាំឆ្នាំឡើងដល់៦,១% នៅដំណាច់ខែមិថុនា ឆ្នាំ២០០៥ មកដល់ដំណាច់ខែសីហានេះ អាត្រាចុះមកត្រឹម ៥,៧% ។ តាមរដូវកាលដែលធ្លាប់គេចំណាំ ហើយដែលធ្លាប់បានកត់ត្រាទុកក្នុងឆ្នាំមុនៗ តាមការគណនាអាត្រានេះ អាចចុះដល់កំរិត ៤,៩% វិញនៅដំណាច់ឆ្នាំ២០០៥នេះ មានន័យថា វាស្ថិតនៅក្នុងកំរិតយើងគ្រប់គ្រងវាបាននៅឡើយ តាមការវិនិច្ឆ័យរបស់ IMS ។ ឯកឧត្តម ថ្លែងថា : ទិន្នន័យផ្សេងៗបានបញ្ជាក់ថា មូលដ្ឋានផ្គត់ផ្គង់ប្រេងឥន្ធនៈនៅចង្អៀត ហើយនឹងបន្តចង្អៀតតទៅទៀត ចំពោះកំណើនទាមទារនៃការប្រើប្រាស់កាន់តែកើនឡើងថែមទៀត ពិសេសតំរូវការចំពោះពលរដ្ឋនៅអាស៊ីកាន់តែមានភាពខ្លាំងក្លាជាងគេ ។/

---

## ឯកឧត្តម សុខ អាន : ទិសដៅជាយុទ្ធសាស្ត្រចំនួន ៧ នៃកំណែទម្រង់ច្បាប់ និងតុលាការ

*AKP ភ្នំពេញ*

ថ្លែងបើកថាក្នុងវេទិកាតុមូលនៃក្លឹបអ្នកកាសែតកម្ពុជា នៅសណ្ឋាគារសាន់វ៉េ ថ្ងៃទី៣១ សីហា ២០០៥ ឯ.ឧ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី បានគូសបញ្ជាក់អំពីទិសដៅជាយុទ្ធសាស្ត្រចំនួន ៧ នៃកំណែទម្រង់ច្បាប់ និងតុលាការ រួមមាន :

១-ទិសដៅជាយុទ្ធសាស្ត្រទី១ គឺពង្រឹងការការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល ។ លទ្ធផលរំពឹងទុក គឺការជំរុញ និងបង្កលក្ខណៈអោយប្រជាពលរដ្ឋគ្រប់រូបអាចអនុវត្តនូវសិទ្ធិ និងសេរីភាពរបស់ពួកគេបាន ។ ដើម្បីទទួលបាននូវលទ្ធផលរំពឹងទុកនេះ យើងត្រូវតែបណ្តុះបណ្តាល និងកសាងកម្មវិធីយល់ដឹងអំពីសិទ្ធិមនុស្ស និងសិទ្ធជាមូលដ្ឋាន រួមទាំងសិទ្ធិពលរដ្ឋនៅថ្នាក់សហគមន៍ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រី កុមារ ជនជាតិភាគតិច និងអ្នកបាត់បង់ឱកាស ។ បណ្តុះបណ្តាលដល់មន្ត្រីនៅក្នុងភ្នាក់ងារអនុវត្តច្បាប់ ។ កសាងនីតិវិធីសំរាប់ស្ថាប័នមួយឯករាជ្យ និងមានប្រសិទ្ធភាពសំរាប់ការចុះបញ្ជីកម្មសិទ្ធិ ។ បង្កើតនូវមុខងារអំប៊ូសម៉ែន ។ល។ ។

២-ទិសដៅជាយុទ្ធសាស្ត្រទី២ គឺធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ ។

លទ្ធផលរំពឹងទុក គឺមានដំណើរតាក់តែងច្បាប់ និងក្របខ័ណ្ឌច្បាប់មួយដែលត្រូវបានធ្វើទំនើបកម្មក្នុងគោលបំណងអនុវត្តនីតិរដ្ឋផ្អែកលើប្រព័ន្ធឋានានុក្រមនៃច្បាប់ ។ យុទសាស្ត្រសំរាប់ទិសដៅទី២ នេះ គឺបំពេញក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងវិស័យច្បាប់ និងតុលាការ ។ ផ្តល់នូវដំណើរតាក់តែងច្បាប់មួយមានប្រសិទ្ធភាព ស៊ីសង្វាក់គ្នា និងមានការចូលរួម ។ បង្កើតច្បាប់ដើម្បីផ្តល់លទ្ធភាពអោយសាធារណជនជ្រួតជ្រាបអំពីដំណើរការតុលាការ ក៏ដូចជាព័ត៏មាន អំពីរដ្ឋបាលគ្រប់គ្រង ។

៣-ទិសដៅជាយុទសាស្ត្រទី៣ គឺផ្តល់លទ្ធភាពទទួលបានព័ត៏មានអំពីច្បាប់ និងយុត្តិធម៌ ។ លទ្ធផលរំពឹងទុក គឺលើកកំពស់ការយល់ដឹងជាសាធារណៈ និងលទ្ធភាពទទួលបានព័ត៏មានច្បាប់ និងយុត្តិធម៌។

ទិសដៅទី៣នេះ ទាមទារអោយមានការបោះពុម្ពផ្សាយជាទៀងទាត់នូវច្បាប់ និងរាល់លិខិតបទដ្ឋានគតិយុត្តិ សេចក្តីសំរេចរបស់តុលាការកំពូល និងសាលក្រមស្តាពររបស់តុលាការជាន់ក្រោម និងធានាអោយអ្នកប្រកបវិជ្ជាជីវៈក្នុងតុលាការ មានសកម្មភាពទទួលបាននូវឯកសារច្បាប់របស់ប្រទេស និងរបស់ស្ថាប័នអន្តរជាតិ ។

៤-ទិសដៅជាយុទ្ធសាស្ត្រទី៤ គឺធ្វើអោយប្រសើរឡើងនូវគុណភាពនៃដំណើររឿងក្តី និងសេវាពាក់ព័ន្ធ ។

លទ្ធផលរំពឹងទុក គឺធានាអោយមានដំណើរការត្រឹមត្រូវនៅមុខអង្គភាពរដ្ឋបាល និងនៅមុខតុលាការ និងសិទ្ធិប្តឹងតវ៉ារបស់ជនគ្រប់រូប ។

ទិសដៅទី៤នេះ ទាមទារអោយមានផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ ស្របទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគ្រប់រូប និងមានគុណភាពខ្ពស់ ។ បង្កើនចំនួនមេធាវី ជាពិសេសនៅតាមបណ្តាខេត្ត និងធានាអោយមានច្បាប់កំណត់អំពីដំណើរការត្រឹមត្រូវ ដែលចៅក្រម មេធាវី មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់គោរពតាម ។

៥-ទិសដៅជាយុទ្ធសាស្ត្រទី៥ គឺពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ ។

លទ្ធផលរំពឹងទុក គឺធានាអោយមានតុលាការមួយឯករាជ្យ និងមានដំណើរការល្អប្រសើរ ។

ដើម្បីទទួលបាននូវលទ្ធផលរំពឹងទុក យើងត្រូវលើកកំពស់តុលាការមួយដែលឯករាជ្យ និងអាចជឿទុកចិត្តបាន មានដំណើរការ និងភារកិច្ចកំណត់ត្រឹមត្រូវ និងការពារដោយច្បាប់ ។ បង្កើនការទទួលខុសត្រូវរបស់តុលាការ និងបង្កើតនូវប្រព័ន្ធមួយមានតម្លាភាព សំរាប់ការតែងតាំងតម្លើងឋានន្តរស័ក្តិ និងថ្នាក់ ប្រាក់បៀវត្សចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការដទៃទៀត ព្រមទាំងវិធានការដាក់វិន័យជាមួយគ្នា និងក្រុមសីលធម៌ ។ ផ្តល់មធ្យោបាយគ្រប់គ្រាន់ដល់តុលាការ រួមមានការផ្តល់ការអប់រំមានគុណភាពសាលាជំរះក្តីបំពាក់ដោយសម្ភារៈគ្រប់គ្រាន់ ។ល។ ។

៦-ទិសដៅជាយុទ្ធសាស្ត្រទី៦ គឺបញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

លទ្ធផល រំពឹងទុក គឺបង្កើតនូវដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានដំណើរការល្អ និងយន្តការសន្ទានកម្ម ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម និងវិវាទតូចតាចនៅថ្នាក់សហគមន៍ ។

ដើម្បីនឹងផ្តល់លទ្ធភាពអោយប្រជាពលរដ្ឋទទួលបាននូវយុត្តិធម៌ និងសំរាលដល់ការងារប្រព័ន្ធតុលាការ ត្រូវបញ្ចូលមជ្ឈត្តកម្មពាណិជ្ជកម្ម និងវិធីសាស្ត្រដោះស្រាយក្រៅប្រព័ន្ធតុលាការដទៃទៀត ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម វិវាទការងារ ។ល។ រៀបចំយន្តការដោះស្រាយវិវាទតូចតាចនៅថ្នាក់សហគមន៍ឱ្យមានប្រសិទ្ធភាព ។

៧-ទិសដៅជាយុទ្ធសាស្ត្រទី៧ គឺពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការ ដើម្បីបំពេញអាណត្តិរបស់ខ្លួនបានសំរេច ។

លទ្ធផលរំពឹកទុក គឺផ្តល់នូវតម្លាភាព និងមធ្យោបាយធ្វើផែនការកម្ម ថវិកាកម្ម ការត្រួតពិនិត្យតាមដាន និងធ្វើរបាយការណ៍ ដើម្បីធានាការអនុវត្តន៍មានការទទួលខុសត្រូវ និងមានប្រសិទ្ធភាព ។

ទិសដៅទី៧នេះ ទាមទារឱ្យមានក្របខ័ណ្ឌច្បាប់មួយ ដែលកំណត់ស្ថាប័នមានរចនាសម្ព័ន្ធ និងអាណត្តិជាក់លាក់សំរាប់វិស័យច្បាប់ និងតុលាការ អភិវឌ្ឍន៍ប្រព័ន្ធត្រួតពិនិត្យដែលអាចវាស់វែងការផ្តល់យុត្តិធម៌ដល់គូក្តី ។ អភិវឌ្ឍន៍វិធីសាស្ត្ររួមមួយដើម្បីធ្វើផែនការកម្ម ថវិកាកម្ម ការត្រួតពិនិត្យសវនកម្ម និងការធ្វើរបាយការណ៍ ។ កសាងសមត្ថភាពចាំបាច់សំរាប់ស្ថាប័នច្បាប់ និងតុលាការ ។ យុទ្ធសាស្ត្រនៃការកសាងសមត្ថភាព ត្រូវភ្ជាប់ទៅនឹងកម្មវិធីកំណែទម្រង់រដ្ឋបាល ។ អភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងធនធានមនុស្ស ។/

---

# ផែនការណែនាំ ស្ដីពីការរៀបចំពិធីបុណ្យ
# កាន់បិណ្ឌ ភ្ជុំបិណ្ឌ ( ១៩ កញ្ញា ដល់ ៣ តុលា )
# និងកឋិនទាន ( ១៩ តុលា ដល់ ១៦ វិច្ឆិកា ២០០៥)

*AKP ភ្នំពេញ*

ផែនការណែនាំ ស្ដីពីការរៀបចំពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងកឋិនទាន ដែលចេញផ្សាយដោយសម្ដេចចៅហ្វាវាំង គង់ សំអុល ប្រធានគណៈកម្មាការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានខ្លឹមសារថា :

-បុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីព្រះពុទ្ធសាសនាដ៏សំខាន់របស់ពុទ្ធបរិស័ទខ្មែរគ្រប់រូប ។ ពិធីនេះប្រារព្ធឡើងដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធនៃអ្នកមានគុណទាំងឡាយ មានមាតាបិតា ជីដូន ជីតា គ្រូឧបជ្ឈាយាចារ្យ បុព្វបុរសជាតិ និងបងប្អូនជនរួមជាតិទាំងឡាយដែលបានលាចាកលោកនេះទៅកាន់លោកខាងមុខ ។ម្យ៉ាងទៀត ពិធីនេះក៏ជាឱកាសជួបជុំឪពុកម្ដាយ បងប្អូន ញាតិមិត្តសាច់សាលោហិតដែលរស់នៅទីផ្សេងៗគ្នា នឹងអាចស្វែងយល់បានពីសុខទុក្ខ និងដំណើរប្រព្រឹត្តទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរវាងគ្នានឹងគ្នាទៅវិញទៅមក ព្រមទាំងអាចបង្កើនបាននូវសាមគ្គីភាពដ៏ទូលំទូលាយផង។

-ឆ្នាំនេះ ពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌនឹងប្រព្រឹត្តទៅពីថ្ងៃ ១រោជ ដល់ថ្ងៃ ១៥រោជ ខែភទ្របទ ត្រូវនឹងថ្ងៃទី១៩ ខែកញ្ញា ដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៥ ។

-បុណ្យកឋិនទាន ជាកាលទានមួយដ៏ថ្លៃថ្លា មានលក្ខណៈពិសេសនៅក្នុងព្រះពុទ្ធសាសនា ដែលក្នុងមួយឆ្នាំមានតែម្ដង មានរយៈកំណត់តែ ២៩ថ្ងៃ វត្តមួយទទួលបានតែអង្គកឋិនមួយ ជាទានមានផលានិសង្សខ្ពស់ទាំងទាយកទាយិកាអ្នកឱ្យ និងទាំងបដិគ្គាហកៈអ្នកទទួលជាទីជ្រះថ្លា និងចំណូលចិត្តរបស់ពុទ្ធបរិស័ទខ្មែរដែលតែងតែប្រារព្ធធ្វើឡើងរៀងរាល់ឆ្នាំ ។ ក្រៅពីនេះ តាមរយៈកឋិនទាន វត្តនិមួយៗក៏មានលទ្ធភាពអាចនឹងទទួលបាននូវសម្ភារៈ ថវិកាយ៉ាងច្រើនបំរើការកសាងទីសេនាសនៈនៅក្នុងវត្ត មានព្រះវិហារ កុដិ សាលា និងជួយឧបត្ថម្ភដល់ការកសាងសមិទ្ធផលសង្គម និងវិស័យសង្គមកិច្ចផងថែមទៀត ។

-ឆ្នាំនេះ កឋិនទាន នឹងត្រូវប្រព្រឹត្តទៅពីថ្ងៃទី ១រោច ខែអស្សុជ ដល់ថ្ងៃ ១៥កើត ខែកត្តិក ត្រូវនឹងថ្ងៃទី១៩ ខែតុលា ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

ដើម្បីបើកឱកាសប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទបំពេញកុសលតាមសទ្ធាតាមជ្រះថ្លា ជូនបុត្តធីតាបងប្អូន សិស្សានុសិស្សមានលទ្ធភាពធ្វើបដិការៈគោរពតបស្នងសងគុណមាតាបិតា ជីដូនជីតា អាណាព្យាបាល គ្រូឧបជ្ឈាយាចារ្យតាមជំនឿ និងបានរួមចំណែកថែរក្សានូវប្រពៃណីទំនៀមទម្លាប់ ជំនឿសាសនា

វប្បធម៌ អរិយធម៌ ដែលជាអត្តសញ្ញាណដ៏ថ្លៃថ្លារបស់ជាតិអោយបានគង់វង្ស គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចតទៅនេះ ៖

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយអំពីខ្លឹមសារពិធីបុណ្យទាំងពីរខាងលើអោយបានជ្រួតជ្រាបទូលំទូលាយ និងបំផុសលើកទឹកចិត្ត បង្កលក្ខណៈងាយស្រួលឱ្យមន្ត្រីរាជការក្នុងឱវាទជាពុទ្ធសាសនិកបានចូលរួមបំពេញបុណ្យកុសលជាប្រពៃណីនៅតាមវត្តអារាម ឬនៅក្នុងអង្គភាពរបស់ខ្លួន ព្រមទាំងបានជួបជុំឪពុកម្តាយ បងប្អូន ជីដូនជីតា តាមបំណងប្រាថ្នា ។

២-ក្រសួងធម្មការ និងសាសនា ត្រូវធ្វើការណែនាំលំអិតដល់មន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង យកចិត្តទុកដាក់បង្កលក្ខណៈអោយបានល្អប្រសើរប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទប្រារព្ធពិធីកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងបុណ្យកឋិនទានតាមប្រពៃណីព្រះពុទ្ធសាសនា និងទំនៀមទំលាប់ជាតិ ដោយសទ្ធាជ្រះថ្លាតាមពេលវេលាកំណត់ ។

គ្រប់វត្តអារាម ត្រូវរៀបចំបោសសំអាតបូជនីយដ្ឋាន ស្តូប កន្លែងតម្កល់អដ្ឋិធាតុបងប្អូនជនរួមជាតិដែលបានបាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ និងរៀបចំបង្សុកូល ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធបុព្វបុរសដែលបានពលីក្នុងបុព្វហេតុជាតិមាតុភូមិ និងជនរួមជាតិយើងទាំងនោះ តាមប្រពៃណីព្រះពុទ្ធសាសនា ។

រាល់ផលទានដែលកើតឡើងដោយពិធីបុណ្យទាំងពីរខាងលើ មានម្ហូបអាហារ នំចំណី ជាដើម គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវមានកម្មវិធីចាត់តាំងចុះសួរសុខទុក្ខនៅតាមមន្ទីរពេទ្យ មណ្ឌលពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យ បងប្អូនខ្វះខាត ដោយអំពាវនាវតាមគ្រប់ក្រសួង ស្ថាប័ន អង្គភាព វត្តអារាម អោយចូលរួមចំណែកតាមលទ្ធភាព ។ ជាពិសេសសម្ភារៈ ថវិកា ត្រូវណែនាំអោយមានការគ្រប់គ្រង និងប្រើប្រាស់ឱ្យបានគត់មត់ សមហេតុសមផល ជៀសវាងការបាត់បង់ដោយប្រការផ្សេងៗ និងបង្កអោយមានទៅជាទំនាស់បែកបាក់សាមគ្គី ដែលនឹងអាចកើតមានជាយថាហេតុ ។

គ្រប់អ្នកផ្តួចផ្តើមដង្ហែអង្គកឋិនត្រូវត្រួតពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយនូវប្រភេទមនុស្ស ដែលចូលរួមដង្ហែអង្គកឋិន ព្រោះអាចមានមនុស្សមិនសុចរិតបង្កសកម្មភាពនាំអោយមានទំនាស់រវាងក្រុមមួយទៅក្រុមមួយ ធ្វើអោយខូចតម្លៃនៃបុណ្យកឋិនទាន ។

៣-អាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវធ្វើការណែនាំ និងអប់រំយុវជន យុវនារី កុមារា កុមារី ដែលចូលរួមដង្ហែអង្គកឋិនអោយយល់ពីតម្លៃនៃពិធីបុណ្យដ៏ឧត្តុងឧត្តម្តនេះ ហើយចេះធ្វើខ្លួនអោយស័ក្តិសមជាកូនចៅរបស់ពុទ្ធសាសនិកពិតប្រាកដ ដោយមិនបង្កសកម្មភាពនាំឱ្យប៉ះពាល់ដល់កិត្តិយសព្រះពុទ្ធសាសនា

ដូចជាការគប់ស្បោងទឹក ជះទឹក គប់អំពៅ គប់ផ្លែឈើ និងគប់វត្ថុរឹងផ្សេងៗ ធ្វើឱ្យខូចរបៀបរៀបរយ សណ្តាប់ធ្នាប់សង្គម និងអាចឈានទៅរកគ្រោះថ្នាក់ដោយអំពើលេងសើចគ្មានរបៀបនេះ ។

៤-ក្រសួងពត៌មាន ត្រូវណែនាំបណ្តាញឃោសនា វិទ្យុ ទូរទស្សន៍ជាតិ និងឯកជន អ្នកយកពត៌មាន តាមដានស្វែងយល់ស្រាវជ្រាវប្រវត្តិខ្លឹមសារ និងសកម្មភាពនៃពិធីបុណ្យប្រពៃណី និងអំពីរបៀបស្លៀកពាក់ ក៏ដូចជាអាកប្បកិរិយា ឫកពាសុភាពរាបសារ ដែលត្រូវប្រកាន់យកក្នុងពេលចូលរួមពិធីនេះ នៅក្នុងវត្តអារាម និងធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយក្នុងរយៈពេលប្រារព្ធពិធីបុណ្យទាំងពីរ ។

៥-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាពក្រោមឱវាទអោយសហការ ការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម បង្កលក្ខណៈប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទបំពេញកុសលតាមជំនឿ និងធានាសុវត្ថិភាពសប្បាយរីករាយ ។

គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណជាតិ-អន្តរជាតិ សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង នឹងចាត់តាំងអនុវត្តតាមស្មារតីនៃសារាចរណែនាំដូចយោងខាងលើ និងផែនការណែនាំនេះ អោយបានសំរេចលទ្ធផលល្អប្រសើរ ស្របតាមប្រពៃណីជាតិដ៏រុងរឿងរបស់យើង ។/

---

## ចិនផ្តល់នាវាប្រដេញ ៦គ្រឿង ដល់កម្ពុជា

*លោក ស្វាយ កេតថាណា AKP ក្រុងព្រះសីហនុ*

នាវាចំនួន ៦គ្រឿង ផលិតនៅប្រទេសចិន ជាប្រភេទនាវាប្រដេញ ត្រូវបានក្រសួងសន្តិសុខសាធារណរដ្ឋប្រជាមានិតចិន ផ្តល់ជាជំនួយឥតសំណងដល់ក្រសួងមហាផ្ទៃកម្ពុជា ហើយពិធីប្រគល់ និងទទួល បានប្រារព្ធធ្វើឡើងនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ កាលពីព្រឹកថ្ងៃទី១ កញ្ញា ឆ្នាំ២០០៩នេះ ។

នាវាប្រដេញទាំង ៦គ្រឿងនេះ មាននាវាកម្លាំង ៥០០សេះ ក្នុងមួយគ្រឿងៗផ្ទុកកងកម្លាំងបាន ៣០នាក់ ចំនួន ៣គ្រឿង និងនាវាធុនតូច មានកម្លាំង ២៥០សេះ ដែលអាចផ្ទុកកងកម្លាំងបាន ១២នាក់ ចំនួន ៣គ្រឿង ។

ក្នុងពិធីប្រគល់ទទួលនាវានេះ ឯកឧត្តម នាយឧត្តមសេនីយ ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានលើកឡើងក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលចិន ដែលបានផ្តល់ជំនួយដ៏មានសារៈសំខាន់នេះ ហើយជាមួយនេះ ជាការរួមវិភាគទានដ៏ខ្លាំងក្លាដ៏មានប្រសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការរបស់កងកម្លាំងនគរបាលជាតិលើផ្ទៃសមុទ្រ ក្នុងការប្រយុទ្ធប្រឆាំងប្រតិកម្មឆ្លងដែនគ្រប់រូបភាព ជាពិសេសការរត់ពន្ធគ្រឿងញៀន ការរត់ពន្ធមនុស្ស និងអំពើឆក់ប្លន់តាមសមុទ្រ ។

នេះជាសក្ខីភាពមួយថ្មីទៀតដែលឆ្លុះបញ្ចាំងឱ្យឃើញចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ ប្រជាជនទាំងពីរ និងដោយឡែករវាងកងកម្លាំងនគរបាលនៃប្រទេសទាំងពីរកាន់តែជិតស្និទ្ធ និងរឹងមាំ ។

ឯកឧត្តម នាយឧត្តមសេនីយ ឯម សំអាន ក៏បានបន្ថែមថា ចំណងសាមគ្គីភាពកម្ពុជា-ចិន គឺជាប្រពៃណីនៃទំនាក់ទំនង ដែលធ្លាប់បានរួមសុខទុក្ខជាមួយគ្នាដ៏យូរលង់មកហើយ រហូតដល់បច្ចុប្បន្ននេះ សម្ព័ន្ធមេត្រីភាព មិត្តភាព និងភាតរភាពរវាងប្រជាជននៃប្រទេសទាំងពីរកាន់តែត្រូវបានពង្រឹងពង្រីកឥតឈប់ឈរ ដែលបានឆ្លុះបញ្ចាំងតាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមកលើគ្រប់វិស័យ ហើយសំខាន់បំផុតនេះ គឺកិច្ចសហប្រតិបត្តិការការពារថែរក្សាសន្តិសុខជាតិនៃប្រទេសទាំងពីរ ។ ដោយឡែកក្នុងកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខទាំងពីរកម្ពុជា-ចិន បានដំណើរការល្អប្រសើរ ជាពិសេសគឺអនុវត្តខ្លឹមសារកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជា និងក្រសួងសន្តិសុខនៃសាធារណរដ្ឋប្រជាមានិតចិនដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ ។ ក្រៅពីនេះកងកម្លាំងនគរបាលជាតិ ក៏បានទទួលនូវការជួយឧបត្ថម្ភគាំទ្រពីសំណាក់ក្រសួងសន្តិសុខនៃសាធារណរដ្ឋប្រជាមានិតចិននូវឧបករណ៍ សម្ភារៈ និងមធ្យោបាយមួយចំនួន មានជាអាទិ៍ដូចជា គ្រុណាត់ឯកសណ្ឋានកងកម្លាំងនគរបាល សម្ភារៈបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ វិទ្យុទាក់ទង រថយន្តស៊ីរ៉ែន រថយន្តពន្លត់អគ្គីភ័យ ម៉ូតូប្រដេញ ជាដើម ។

អញ្ជើញចូលរួមក្នុងពិធីប្រគល់ និងទទួលនេះ មានទីប្រឹក្សាសេដ្ឋកិច្ចអមស្ថានទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា អភិបាលក្រុងព្រះសីហនុ អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ អាជ្ញាធរគ្រប់ជាន់ថ្នាក់នាយនគរបាល មន្ត្រីរាជការ ជាច្រើនកុះករ ។/

---

## ឯកឧត្តម ច័ន្ទ សារុន ទាមទារឱ្យកសិករធ្វើការផ្លាស់ប្តូរឥរិយាបថចំនួនពីរ ទើបយើងមានស្បៀងគ្រប់គ្រាន់

*លោក បាល់ សុង AKP ភ្នំពេញ*

ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានចោទសួរដោយក្រុមកម្មសិក្សាការីពីគោលនយោបាយរបស់ក្រសួង ចំពោះវិស័យកសិកម្ម ដែលធ្វើឱ្យកសិករមានស្បៀងគ្រប់គ្រាន់ក្នុងពេលដែលផ្ទៃដីនៅដដែល ហើយមនុស្សចេះតែកើនឡើង ។

ឯកឧត្តម រដ្ឋមន្ត្រីបានធ្វើការបំភ្លឺថា ៖ ដំណោះស្រាយ គឺការបង្កើនទិន្នផលកសិកម្មនៅលើផ្ទៃដីដដែល ។ ដើម្បីសំរេចបានបញ្ហានេះ ទាមទារឱ្យកសិករយើងធ្វើការផ្លាស់ប្តូរឥរិយាបថចំនួនពីរ គឺទី ១

ការប្រើប្រាស់ពូជស្រូវ និងទី ២ ការប្រើប្រាស់បច្ចេកទេសធ្វើប្រពលវប្បកម្មតាមគោលការណ៍ធម្មជាតិបែបថ្មី ។ ឯកឧត្តមរដ្ឋមន្ត្រីបានពន្យល់ថា ការប្រើប្រាស់ពូជស្រូវធ្ងន់លែងសមស្របសម្រាប់កសិករធ្វើការដាំដុះនាពេលនេះតទៅទៀតហើយ តែកសិករមានទម្លាប់ក្នុងការប្រើប្រាស់ពូជស្រូវនេះ ។ ការសមស្រប គឺត្រូវផ្លាស់ប្តូរមកប្រើប្រាស់ស្រូវស្រាល ឬពូជស្រូវកណ្តាល "ពូជស្រូវសែនពិដោរ" ដែលមិនប្រកាន់រដូវ និងមានរយៈពេលដាំដុះខ្លី តែទទួលបានទិន្នផលខ្ពស់ ចាប់ពី ៣,៥តោន ទៅ ៥តោន ជាមធ្យម ។ ពូជបច្ចុប្បន្នបានទទួលផលគឺ ១,៩តោន ទៅ ២តោនប៉ុណ្ណោះក្នុងមួយហិកតា ។

ឯកឧត្តម រដ្ឋមន្ត្រីបានបន្តទៀតថា យើងត្រូវធ្វើការផ្លាស់ប្តូរបច្ចេកទេសដាំដុះថ្មី គឺការធ្វើប្រពលវប្បកម្មតាមគោលការណ៍ធម្មជាតិដោយរបៀបស្ទូងស្រូវមួយដើម ។ បច្ចេកទេសថ្មីនេះ កំពុងទទួលបានជោគជ័យនៅស្រុកត្រាំកក់ ខេត្តតាកែវ និងកំពុងបន្តផ្សព្វផ្សាយធ្វើបង្ហាញទៅកាន់ខេត្តដទៃទៀត ។ លោកបានបញ្ជាក់ថា បច្ចេកទេសថ្មី ការស្ទូងស្រូវមួយដើមបានធ្វើឱ្យយើងចំណេញពូជស្រូវ ប្រើប្រាស់ពលកម្មតិច មិនប្រើជីគីមី តែបានទទួលទិន្នផលខ្ពស់ ។ លោកបានបន្តថា ខណៈនេះក្រសួងកសិកម្មបានកំពុងជំរុញធ្វើការផ្សព្វផ្សាយបច្ចេកទេសថ្មី និងណែនាំដល់កសិករឱ្យធ្វើការផ្លាស់ប្តូរឥរិយាបថទាំងពីរនេះយ៉ាងសកម្ម ។

ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មបានធ្វើការពន្យល់នេះក្នុងឱកាសដែលឯកឧត្តមអញ្ជើញថ្លែងនៅក្នុងបទបង្ហាញមួយនៅសាលាភូមិន្ទរដ្ឋបាលកាលពីថ្ងៃទី៣១ សីហា ២០០៥នេះ នៅចំពោះមុខកម្មសិក្សាការីចំនួន ២៣៨នាក់ ដែលបានចូលរួម ។

នៅក្នុងការធ្វើបទបង្ហាញនេះដែរ ឯកឧត្តម រដ្ឋមន្ត្រី បានធ្វើការគូសបញ្ជាក់អំពីរចនាសម្ព័ន្ធ និងយន្តការនានារបស់ក្រសួងកសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងធ្វើការអធិប្បាយទៅលើយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះ ចតុកោណទី១ គឺការលើកស្ទួយវិស័យកសិកម្ម ។ លោករដ្ឋមន្ត្រីក៏បានបើកវេទិការសេរីឱ្យកម្មសិក្សាការីចោទជាសំនួរផ្សេងៗជាច្រើនជុំវិញវិស័យកសិកម្ម និងវិធានការចំពោះមុខដែលក្រសួងប្រកាន់យក ។

ឯកឧត្តម រដ្ឋមន្ត្រីបានបញ្ជាក់អំពីសកម្មភាពជាក់ស្តែងមួយចំនួនធំដែលក្រសួងកំពុងចុះអនុវត្តជាក់ស្តែងជាមួយប្រជាជន ជំរុញឱ្យប្រជាជនធ្វើពិពិធកម្មកសិកម្ម ។ ការខំប្រឹងប្រែងរបស់ក្រសួងក្នុងការជំរុញផលិតផលកសិកម្មសម្រាប់ការនាំចេញ មានស្រូវ បន្លែ ។ល។ បទបង្ហាញក៏បានបញ្ជាក់ផងដែរអំពីស្ថានភាពកសិកម្ម ហើយអ្វីដែលឯកឧត្តមរដ្ឋមន្ត្រីព្រួយបារម្ភ គឺបញ្ហាទឹកជំនន់ដែលអាចកើតឡើងជាយថាហេតុ។

ឯកឧត្តម ច័ន្ទ សារុន បានមានប្រសាសន៍បញ្ជាក់ថា ក្នុងស្ថានភាពនាពេលបច្ចុប្បន្ន មានតែការផ្លាស់ប្តូរឥរិយាបថនៅក្នុងការដាំដំណាំស្រូវក្នុងចំណោមកសិករនៅទូទាំងប្រទេស ។

ឯកឧត្តម បានបន្តទៀតថា ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ពិសេសសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្រសួងកសិកម្មបានធ្វើការណែនាំដល់កសិករឱ្យធ្វើការផ្លាស់ប្តូរទម្លាប់ចាស់ ដោយងាយមករក ការធ្វើរបៀបថ្មី ដែលផ្តល់នូវគុណប្រយោជន៍ខ្ពស់វិញដល់ខ្លួនជាមានបញ្ហាសំខាន់ ។/

---

# ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
# ប្រកាសយកពន្ធបន្ថែម ២% លើពន្ធ VAT ផ្នែកសណ្ឋាគារ

*លោក អ៊ុក សាផាន AKP ភ្នំពេញ*

ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ បានមានប្រសាសន៍ថា: ការបន្ថែម២% លើពន្ធ VAT ១០% លើសណ្ឋាគារនោះ គឺបានចូលជាធរមានចាប់ពីខែកញ្ញា ២០០៩នេះទៅ ។ នេះបើតាមមតិរបស់ក្រសួងហិរញ្ញវត្ថុប្រកាស ។

ទាក់ទិនការបន្ថែម ២% នេះថា តើវានឹងប៉ះពាល់អ្វីខ្លះទៅលើអ្នករកស៊ីវិនិយោគសណ្ឋាគារនោះ? ឯកឧត្តម ថោង ខុន បានបញ្ជាក់ថា តាមធម្មតាទាំងអស់គ្នាកំពុងនិយាយពីបញ្ហាកាត់បន្ថយថ្លៃទស្សនកិច្ច ប៉ុន្តែរឿងក្រសួងហិរញ្ញវត្ថុតម្លើង ២% នេះ ខ្ញុំមិនទាន់មានយោបល់ទេ ដោយហេតុថា មិនចូលរួមប្រជុំជាមួយក្រសួងហិរញ្ញវត្ថុ ។ ប៉ុន្តែខ្ញុំអាចនិយាយថា ការតម្លើង ២% នេះ ប្រហែលជាមានហេតុផលរបស់គេ អាចថា បន្ថយផ្នែកណាមួយផ្សេង ហើយមកបូកនឹងថ្លៃនេះ គឺវានៅតែតម្លៃដដែល ឬចុះតម្លៃ ។

ឯកឧត្តម ថោង ខុន ក៏បានបដិសេធមិនព្រមធ្វើអត្ថាធិប្បាយអ្វីឱ្យច្រើនលើសពីនេះនូវបញ្ហានេះទេ ប៉ុន្តែឯកឧត្តមគិតថា ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុធ្វើការនេះ បែបមានហេតុផលច្បាស់លាស់ ។

ឯកឧត្តមបានលើកឧទាហរណ៍ថា គេគ្រាន់តែធ្វើការវិនិយោគទៅលើផ្លូវទៅកាន់តំបន់ទេសចរណ៍មួយដ៏ធំនោះ ថ្លៃដឹកជញ្ជូនគឺវាថោកទៅហើយ ។ ជាក់ស្តែងបើតាមយន្តហោះពីភ្នំពេញទៅមកសៀមរាបតម្លៃជាង ១០០ដុល្លារអាមេរិក តែបើតាមរថយន្តមិនដល់ ២០ដុល្លារ ទេ ។

ឯកឧត្តម បញ្ជាក់ថា : ខ្ញុំមិនធ្វើអត្ថាធិប្បាយថា ការតម្លើងតម្លៃ ២% នេះវាប៉ះពាល់ទៅលើពាណិជ្ជកម្មទេសចរណ៍ទេ ។ យើងមិនប្រាកដថា ការតម្លើងថ្លៃ ២% វាប៉ះនោះទេ ។ បើយើងនិយាយពីតម្លៃសណ្ឋាគារបច្ចុប្បន្ននៅកម្ពុជា បើប្រៀបធៀបនឹងប្រទេសដទៃយើងមិនថ្លៃដូចគេទេ សេវាក៏មិនអន់ជាងគេទេ ហើយសណ្ឋាគារយើងល្អៗទៀតផង ។

ទាក់ទងដល់ការលើកទឹកចិត្តដល់អ្នកវិនិយោគសណ្ឋាគារនោះ ឯកឧត្តម ថោង ខុន បានបញ្ជាក់ថា យើងមិនលើកទឹកចិត្តឱ្យវិនិយោគសណ្ឋាគារនៅភ្នំពេញ និងសៀមរាប ក្រោមផ្កាយ៤ទេ គឺយើងលើក

ទឹកចិត្តឱ្យវិនិយោគសណ្ឋាគារផ្កាយ៤ ផ្កាយ៥ ។ នៅតំបន់មួយចំនួនទៀត ក៏យើងមិនលើកទឹកចិត្តឱ្យវិនិយោគសណ្ឋាគារថ្នាក់ផ្កាយបន្តបន្ទាប់តាមតំបន់នោះផងដែរ ។

ឯកឧត្តម រដ្ឋលេខាធិការ ថោង ខុស ក៏បានឱ្យដឹងថា នៅទូទាំងប្រទេសកម្ពុជាមានសណ្ឋាគារថ្នាក់ផ្កាយ៥ ចំនួន៧ ដែលក្នុងនោះ នៅភ្នំពេញ មាន ២ និងនៅសៀមរាប មាន ៥ ។ សណ្ឋាគារទូទាំងប្រទេសពីថ្នាក់ផ្កាយ១ រហូតដល់ផ្កាយ៥ មានចំនួន ៣០៧ មានបន្ទប់ចំនួន ១៥.១១៦បន្ទប់ ក្នុងចំនួននេះ បើយើងគិតតែក្រុងភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ មានសណ្ឋាគារសរុបចំនួន ២៤៥ ។

ដោយឡែកសមាគមសណ្ឋាគារបានធ្វើការស្នើសុំឱ្យរាជរដ្ឋាភិបាលកុំឱ្យយកពន្ធបន្ថែម ២% លើពន្ធ VAT នេះ ព្រោះថាឥឡូវនេះភ្លើងក៏ឡើងថ្លៃ សណ្ឋាគារក៏កើតច្រើន ។ ដូច្នេះវាមានការប៉ះពាល់ជាខ្លាំងទៅដល់របររកស៊ីផ្នែកនេះ ។/

---

## រំលឹកខួបអនុស្សាវរីយ៍លើកទី ៦០
## ទិវាបុណ្យជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
## ០២ កញ្ញា ១៩៤៥ ‑ ០២ កញ្ញា ២០០៥

*AKP ភ្នំពេញ*

អត្ថបទថ្លែងដោយឯកឧត្តម ង្វៀន ចៀនថាំង ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំនៅកម្ពុជា មានខ្លឹមសារថា ៖

មុននេះ ៦០ឆ្នាំ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ នាទីលាន Ba Dinh ជាប្រវត្តិសាស្ត្រ លោកប្រធាន Ho Chi Minh អគ្គមគ្គុទេសដ៏មហិមាជាទីគោរពរបស់យើងខ្ញុំ បានថ្លែងសេចក្តីប្រកាសឯករាជ្យបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលបច្ចុប្បន្ននេះហៅថា សាធារណរដ្ឋសង្គមនិយមវៀតណាម ។

បើប្រៀបធៀបទៅនឹង ៤.០០០ឆ្នាំ ជាប្រវត្តិសាស្ត្រនៃការកសាង និងការពារថែរក្សាទឹកដីរបស់ប្រជាជាតិវៀតណាម គឺ ៦០ឆ្នាំ ពុំមែនជារយៈកាលមួយដ៏វែងទេ ។ ក៏ប៉ុន្តែរយៈពេល ៦០ឆ្នាំកន្លងទៅជាតំណាក់កាលមួយប្រកបដោយវីរភាពក្នុងទំព័រប្រវត្តិសាស្ត្ររបស់ប្រជាជាតិវៀតណាមយើងខ្ញុំ។ ផ្តើមចេញពីប្រទេសកសិកម្មអន់ថយនិងក្រីក្រ ត្រូវបានពួកអាណានិគមនិយមត្រួតត្រា ហើយបានទទួលរងនូវសង្គ្រាមបំផ្លិចបំផ្លាញជាបន្តបន្ទាប់ ថ្ងៃនេះសាធារណរដ្ឋសង្គមនិយមវៀតណាមបានក្លាយទៅជាប្រទេសមួយឯករាជ្យអធិបតេយ្យភាពពិតប្រាកដ មានស្ថេរភាព និងអភិវឌ្ឍន៍ ជណ្តើមបានសមិទ្ធផលដ៏ធំធេងលើគ្រប់វិស័យ

រួមមានការអភិវឌ្ឍន៍សេដ្ឋកិច្ច វប្បធម៌សង្គម ។ល។ ហើយកំពុងបោះជំហានយ៉ាងរឹងមាំលើដំណើរផ្លូវឧស្សាហូបនីយកម្ម ទំនើបភាវូបនីយកម្មទឹកដី ដើម្បីឆ្ពោះទៅរកគោលដៅ "ប្រជាជនសំបូរ ប្រទេសជាតិខ្លាំងក្លា សង្គមមានសមភាពប្រជាធិបតេយ្យ និងអរិយធម៌" ។ នៅលើឆាកអន្តរជាតិ អត្ថិភាព និងកិត្យានុភាពរបស់វៀតណាមពីមួយថ្ងៃទៅមួយថ្ងៃត្រូវបានពង្រីក និងពង្រឹង ។ សាធារណរដ្ឋសង្គមនិយមវៀតណាមបានក្លាយជាសមាជិករបស់បណ្ដាអង្គការអន្តរជាតិធំៗ ក៏ដូចជានៅក្នុងតំបន់ រួមមាន អង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធអាស៊ាន ARF APEC ASEM ។ល។ ដោយមានគោលនយោបាយបរទេសបើកទូលាយបច្ចុប្បន្ននេះសាធារណរដ្ឋសង្គមនិយមវៀតណាមមានទំនាក់ទំនងការទូតជាមួយ ១៦៧ ប្រទេស ព្រមទាំងមានទំនាក់ទំនងលើផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយ ១៦៥ប្រទេស និងបណ្ដាតំបន់លើពិភពលោក ។ សមិទ្ធផលរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមទាំងនេះ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងសន្តិភាព ស្ថេរភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍ក្នុងតំបន់អាស៊ីភាគអគ្នេយ៍ ក៏ដូចជាលើពិភពលោកទាំងមូល ។

ដោយទទួលបានលទ្ធផលដ៏ល្អប្រពៃក្នុង ៦០ឆ្នាំកន្លងទៅ ថ្ងៃនេះប្រជាជនវៀតណាមយើងខ្ញុំប្រារព្ធខួបទី ៦០ឆ្នាំ នៃថ្ងៃបុណ្យជាតិវៀតណាមក្នុងបរិយាកាសប្រកបដោយមោទនភាពយ៉ាងក្រៃលែង ។

ក្នុងបរិយាកាសដ៏សែនរីករាយនេះ ក្នុងនាមជាឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដ៏រុងរឿង ខ្លួនខ្ញុំផ្ទាល់មានសេចក្ដីរីករាយ និងរំភើបក្រៃលែងដោយឃើញផ្ទាល់នឹងភ្នែកនាពេលថ្មីៗនេះចំពោះការរីកចំរើននូវចំណងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការភូមិផងរបងជាមួយគ្នា ជាអ្នកជិតខាងល្អប្រពៃរវាងប្រទេសទាំងពីរ វៀតណាម-កម្ពុជា ។ ប្រទេសទាំងពីរបានផ្លាស់ប្ដូរគណៈប្រតិភូជាន់ខ្ពស់ជាច្រើន ទន្ទឹមនឹងនេះក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការថ្មី បង្កជាមូលដ្ឋានងាយស្រួលឱ្យកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរបានរីកចំរើនគ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ ។ ទំនាក់ទំនងរវាងមជ្ឈដ្ឋាន និងអង្គការមហាជននានារបស់ប្រទេសទាំងពីរ ក៏បានជួបប្រាស្រ័យទំនាក់ទំនងជាប្រចាំ រួមចំណែកយ៉ាងសកម្មក្នុងការបង្កើនការយល់ដឹង និងរឹតចំណងសាមគ្គីភាពរវាងប្រជាជាតិទាំងពីរថែមទៀត ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ តាងនាមរដ្ឋាភិបាល និងប្រជាជនវៀតណាម ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាដែលបានជួយឧបត្ថម្ភ និងគាំទ្រនូវបុព្វហេតុតស៊ូរំដោះប្រជាជាតិវៀតណាមយើងខ្ញុំមុននេះក៏ដូចជាក្នុងការកសាង និងការពារមាតុភូមិវៀតណាមបច្ចុប្បន្ន ។ ទន្ទឹមនឹងនេះក៏បានរួមជាមួយយើងខ្ញុំ ក្នុងការកសាងចំណងមិត្តភាពរវាងប្រទេសទាំងពីរពីមួយថ្ងៃទៅមួយថ្ងៃឱ្យកាន់តែរឹងមាំ រួមចំណែកក្នុងការធ្វើឱ្យមានស្ថេរភាព និងសំបូររុងរឿងក្នុងប្រទេសយើងទាំងពីរ ក៏ដូចជាក្នុងតំបន់អាស៊ីភាគអគ្នេយ៍ ។

ក្នុងឱកាសខួបអនុស្សាវរីយ៍ទិវាបុណ្យជាតិ ដ៏ឱឡារិកឡារបស់សាធារណរដ្ឋសង្គមនិយមវៀតណាម នេះ ខ្ញុំសូមសំដែងនូវការគោរព និងកោតសរសើរដ៏ខ្ពង់ខ្ពស់ទូលថ្វាយ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះរាជបិតា នរោត្តម សីហនុ ព្រះវររាជមាតា នរោត្តម មុនីនាថ សីហនុ ថ្នាក់ដឹកនាំ សមាជិករង្គនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ព្រមទាំងប្រជាពលរដ្ឋទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា ហើយសូមបួងសួងសូមឱ្យមានសុខភាពល្អ និងវិបុលភាព ។

សូមជូនពរ សូមឱ្យមិត្តភក្តិរបស់ប្រជាជនវៀតណាម និងប្រជាជនកម្ពុជាមានសុខភាពល្អបរិបូរណ៍ ជោគជ័យ និងរុងរឿង ។

សូមប្រសិទ្ធពរជ័យ សូមឱ្យចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ រវាងវៀតណាម និងកម្ពុជា ត្រូវបានពង្រីក និងពង្រឹងឥតឈប់ឈរ ។/

---

## សង្ខេបប្រវត្តិសាស្ត្រ និងសមិទ្ធិសេដ្ឋកិច្ចវប្បធម៌ សង្គមកិច្ច របស់វៀតណាម ៦០ឆ្នាំ កន្លងមក

*AKP ភ្នំពេញ*

ខែសីហា ឆ្នាំ១៩៤៥ ប្រជាជនវៀតណាមទទួលបានជោគជ័យ នៃការបដិវត្តន៍ ។ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ នៅមហាទីធ្លា បាឌីញ (ហាណូយ) លោកប្រធាន ហូ ជីមិញ បានប្រកាសសេចក្តីថ្លែងការឯករាជ្យ បង្កើតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។

ក្រោយពេលបដិវត្តន៍ ខែសីហា ទទួលបានជោគជ័យ ប្រជាជនវៀតណាម ត្រូវប្រឈមមុខនឹងឧបាយកល និងសកម្មភាពឈ្លានពានរបស់សត្រូវច្រើនប្រភេទពីខាងក្រៅ ។ ឆ្នាំ១៩៤៦ ពួកអាណានិគមបារាំងវិលត្រលប់មកឈ្លានពានឥណ្ឌូចិន ។ ប្រជាជនវៀតណាមក្រោមការដឹកនាំរបស់បក្សកុម្មុយនីសឥណ្ឌូចិន (ឥឡូវនេះ គឺជាបក្សកុម្មុយនីសវៀតណាម) និងលោកប្រធាន ហូ ជីម៉ិញ បានដំណើរការការតស៊ូការពារខឿនឯករាជ្យជាតិរបស់ខ្លួន ។ ជ័យជំនះប្រវត្តិសាស្ត្របានបញ្ចប់ការតស៊ូដ៏យូរអង្វែង និងលំបាកវេទនាលើកដំបូងរបស់ប្រជាជនវៀតណាម ។ ដោយមានសន្ធិសញ្ញា Geneve (7-1954) ឯករាជ្យ ឯកភាព នឹងបូរណភាពទឹកដីរបស់វៀតណាម ត្រូវបានសកលលោកទទួលស្គាល់ជាផ្លូវការ ។

ក្រោយពេលដែលអាណានិគមបារាំង បានដកចេញពីភាគខាងជើងទឹកដីវៀតណាម ត្រូវនឹងខ្សែស្របលេខ ១៧ កាត់ជាពីរ ។ ភាគខាងជើងវៀតណាមដំណើរការការកសាងទឹកដីឡើងវិញ និងនៅ

ភាគខាងត្បូងនៅតែមានសង្គ្រាមរវាងម្ខាង គឺប្រជាជនវៀតណាមខាងត្បូង និងម្ខាងទៀត គឺរដ្ឋការសាយហ្គន (Saigon) និងទ័ពអាមេរិក ។

ប្រជាជនវៀតណាមជាថ្មីម្តងទៀត ត្រូវរងគ្រោះសង្គ្រាមដ៏កាចសាហាវជិត ២០ឆ្នាំ ដើម្បីដណ្តើមឯករាជ្យ ប្រជាជាតិឡើងវិញ ។ ក្រោយសន្ធិសញ្ញាប៉ារីស (១៩៧៣) កងទ័ពអាមេរិកត្រូវដកចេញទាំងអស់ពីវៀតណាម ។ ជ័យជំនះនិទាឃរដូវឆ្នាំ១៩៧៥ និងយុទ្ធនាការហូជីមិញជាប្រវត្តិសាស្ត្របានវាយរំលំរដ្ឋការសាយហ្គន (SAIGON) ។ ប្រទេសវៀតណាមបានឯកភាពទាំងស្រុង ហើយបានដាក់ឈ្មោះថ្មី គឺសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានទីក្រុងហាណូយជារដ្ឋធានី ។ តាំងពីពេលនោះមកប្រជាជនវៀតណាមចាប់ផ្តើមដោះស្រាយនូវរាល់ផលវិបត្តិដ៏ធ្ងន់ធ្ងរ ដែលសង្គ្រាមអស់រយៈពេល ៣០ឆ្នាំបានបន្សល់ទុក និងកសាងទឹកដីឡើងវិញ ។ សព្វថ្ងៃនេះប្រជាជាតិវៀតណាមកំពុងឈានចូលសករាជថ្មីមួយ គឺជាសករាជកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីសំរេចទិដៅ គឺប្រជាជនសំបូរ ប្រទេសខ្លាំងក្លា សង្គមមានសកម្មភាពប្រជាធិបតេយ្យ និងអរិយធម៌ ។

ចាប់តាំងពីមហាសន្និបាតលើកទី៦ របស់បក្សកុម្មុយនីសវៀតណាមឆ្នាំ១៩៨៦ ប្រជាជនវៀតណាមដើរតាមមាគ៌ាកែទម្រង់ (ដូយមឺយ) របស់បក្ស ហើយមកដល់ឥឡូវនេះក៏ទទួលបានសមិទ្ធផលដ៏ធំធេងជាច្រើន ធ្វើឱ្យប្រទេសជាតិមានការផ្លាស់ប្តូរលើគ្រប់វិស័យ ដូចជា :

-រក្សាខ្ជាប់នូវល្បឿនសេដ្ឋកិច្ច គឺគិតជាមធ្យមក្នុងដំណាក់កាលពីឆ្នាំ១៩៩៣-១៩៩៧ កើនឡើង ៩% ក្នុងមួយឆ្នាំ ក្រោយមកមានការបន្ថយដោយរងនូវការជះឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ចនៅទ្វីបអាស៊ី ។ ក្នុងតំណាក់កាល២០០០-២០០៤ គិតជាមធ្យមក្នុងមួយឆ្នាំកើន ៧% ។

-ជីវភាពរបស់ប្រជាជនវៀតណាម មានការលើកតំកើងច្បាស់លាស់ពីប្រទេសក្រីក្រខ្វះខាតស្បៀងអាហារ ប៉ុន្តែសព្វថ្ងៃវៀតណាមមិនត្រឹមតែផ្គត់ផ្គង់ជូនប្រជាជនក្នុងប្រទេសគ្រប់គ្រាន់ ថែមទាំងនៅមានអង្ករនាំចេញ ហើយជាប្រទេសឈរឈ្មោះទី២ នៅលើសកលលោកក្នុងការនាំចេញអង្ករ ។ ជាងនេះទៅទៀតវៀតណាម ត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសនៅលើសកលលោកទទួលបានជោគជ័យធំបំផុតក្នុងវិស័យលុបបំបាត់ភាពក្រីក្រ ។

-សភាពការណ៍នយោបាយសង្គម ត្រូវបានការពារយ៉ាងរឹងមាំ និងមានស្ថេរភាព ។

-ទំនាក់ទំនងការបរទេសបានពង្រីកជាងពេលណាណាទាំងអស់ ។

-កិត្យានុភាព និងតួនាទីលើឆាកអន្តរជាតិពីមួយថ្ងៃទៅមួយថ្ងៃកាន់តែបានពង្រីក ។/